# សន្និសីទតស៊ូមតិថ្នាក់ជាតិលើកទី៩ស្តីពី
# ធ្វើការរួមគ្នាដើម្បីលើកកម្ពស់ គណនេយ្យភាពសង្គម លើអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិនៅកម្ពុជា

### រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥

យើងជាតំណាងសហគមន៍មកពីខេត្ត បាត់ដំបង កំពង់ស្ពឺ បន្ទាយមានជ័យ ពោធិសាត់ រតនៈគីរី មណ្ឌលគីរី ព្រះវិហារ កោះកុង ស្ទឹងត្រែង កំពង់ធំ កំពង់ឆ្នាំង ព្រះសីហនុ ស្វាយរៀង កំពត ក្រចេះ ព្រៃវែង កណ្តាល ភ្នំពេញ និងអង្គការសង្គមស៊ីវិលរួមមាន សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC) វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ(API) គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា(CHRAC) សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូល ធនធាន(CRRT) ស្ម័គ្រចិត្តដើម្បីសង្គម(CVS) អង្គការអភិវឌ្ឍន៍និងភាពជាដៃគូរក្នុងសកម្មភាព (DPA) អង្គការយេនឌ័រនិងការអភិវឌ្ឍន៍ដើម្បីកម្ពុជា(GAD/C) ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF) អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច(ICSO) អង្គការយុវជនខ្មែរនិងការអភិវឌ្ឍន៍ សង្គម(KYSD) អង្គការជីវិតថ្លៃថ្នូរ(LWD) អង្គការស្តារកម្ពុជា(Star Kampuchea) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (The NGO Forum on Cambodia) អង្គការវីជីឡែន (Vigilance) អង្គការទស្សនៈពិភពលោក (WVC) អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន(YRDP) អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង(UPWD) មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍(CLEC) និងអង្គការសង្គមស៊ីវិលផ្សេងៗ ប្រមាណ៣៩០នាក់នៅកម្ពុជា សូមធ្វើសេចក្តីថ្លែងការណ៍រួមគ្នាមួយចេញពីបញ្ហាក្នុងសន្និសីទតស៊ូមតិថ្នាក់ជាតិប្រចាំឆ្នាំ លើកទី៩ស្តីពី **“ធ្វើការរួមគ្នាដើម្បីលើកកម្ពស់ គណនេយ្យភាពសង្គម លើអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិនៅកម្ពុជា”** ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។

យើងជាសហគមន៍ និងអង្គការសង្គមស៊ីវិល មកពីខេត្តទាំងអស់ខាងលើនៅកម្ពុជាសូមធ្វើការកោតសរសើរចំពោះការខិតខំរបស់រាជរដ្ឋាភិបាល ដើម្បីជម្រុញកំណែទម្រង់អភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា។ សន្និសីទ តស៊ូមតិថ្នាក់ជាតិប្រចាំឆ្នាំលើកទី៩ សូមលើកឡើងនូវបញ្ហាដែលជាការព្រួយបារម្ភ និងអនុសាសន៍ពាក់ព័ន្ធនឹងផលប៉ះពាល់ធ្ងន់ធ្ងរមួយចំនួនដូចខាងក្រោម៖

## ១). ប្រធានបទ៖ បញ្ហាដីធ្លី (វិវាទដីធ្លី ការបណ្តេញចេញដោយបង្ខំ)

## សមិទ្ធផលរបស់រាជរដ្ឋាភិបាល

ជាការឆ្លើយតបរាជរដ្ឋាភិបាលកម្ពុជាខិតខំប្រឹងប្រែង ក្នុងការដោះស្រាយវិវាទដីធ្លី ដូចជា៖ ដកហូតចំពោះក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណសម្បទានដីសេដ្ឋកិច្ចហើយ មិនបានគោរពតាមច្បាប់ និងកិច្ចសន្យា ព្រមទាំងបន្ថយថេរវេលានៃសម្បទានសេដ្ឋកិច្ចពី ៩៩ឆ្នាំ មក៥០ឆ្នាំ។ លើសពីនេះរាជរដ្ឋាភិបាលបាន បង្កើតនូវគោលនយោបាយដីធ្លី និងធ្វើសេចក្តីព្រាង ក្របខ័ណ្ឌយុទ្ធសាស្រ្តជាច្រើនពាក់ព័ន្ធវិស័យ ដីធ្លី និងការអភិវឌ្ឍន៍ទីក្រុង។

### បញ្ហាប្រឈម

បច្ចុប្បន្ន ប្រជាពលរដ្ឋនៅតែបន្តរងទុក្ខវេទនាដោយសារ វិវាទដីធ្លី និងការបណ្តេញចេញដោយបង្ខំ នៃគម្រោងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ជាហេតុនាំឲ្យប៉ះពាល់ជីវភាព របស់ប្រជាពលរដ្ឋជាពិសេសស្រ្តី និងកុមារ។ ការអភិវឌ្ឍទាំងនេះបានធ្វើឲ្យប្រជាពលរដ្ឋជួបការលំបាកជាងមុនពេលមានគម្រោងអភិវឌ្ឍន៍ ដោយសារវិវាទដីធ្លីមិនត្រូវបានដោះស្រាយ ឲ្យទាន់ពេលវេលា និងចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ជាពិសេសការដោះស្រាយមិនមានភាពយុត្តិធម៌ សំណងមិនសមរម្យ និងមានការរើសអើង (ឧទាហរណ៍៖ក្រុមហ៊ុនយូនៀនឌីវេឡុបមិននៅខេត្តកោះកុង និងក្រុមអូស៊ីអាយស៊ីភ្នំពេញ)។ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋកំពុងប្រឈមនឹងអសុវត្ថិភាព ក្នុងការគ្រប់គ្រងដីធ្លី ដូចជាគ្មានប័ណ្ណកម្មសិទ្ធិ ការចេញប័ណ្ណកម្មសិទ្ធិជាន់គ្នា ការកំណត់ព្រំប្រទល់រដ្ឋបាលមិនច្បាស់លាស់ និងការទន្ទ្រានរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ធំលើដីប្រជាពលរដ្ឋ និងសហគមន៍លើសពីទំហំដីដែលកំណត់ក្នុងអាជ្ញាប័ណ្ណ។ ទោះបីជារាជរដ្ឋាភិបាលបានបញ្ឈប់ការ ផ្តល់ដីសម្បទានសេដ្ឋកិច្ចក្នុងទំហំធំ និងរយៈពេលវែង ព្រមទាំងបានដកហូតដីសម្បទានសេដ្ឋកិច្ច ពីក្រុមហ៊ុនមួយចំនួនដែលមិនអនុវត្តកិច្ចសន្យាជាមួយ រាជរដ្ឋាភិបាលក៏ដោយ ប៉ុន្តែផលប៉ះពាល់នៅតែបន្តកើតមានចំពោះដីលំនៅដ្ឋាន ដីចំការ ដីស្រែ និង ដីព្រៃសហគមន៍របស់ប្រជាពលរដ្ឋ។ ការមិនអនុវត្តន៍តាមរូបមន្តស្បែកខ្លារបស់រាជរដ្ឋាភិបាល និងក្រុមហ៊ុនអភិវឌ្ឍន៍នៅតែជាបញ្ហាធ្ងន់ធ្ងរចំពោះប្រជាពលរដ្ឋ។ គោលនយោបាយចាស់សកម្មភាពថ្មី ដែលមានក្រុមនិស្សិតចុះវាស់វែងដីធ្លី បានបន្សល់នូវជម្លោះដីធ្លី មិនទាន់ដោះស្រាយចប់ដូចជា ការវាស់វែងដីខុសម្ចាស់ ការរារាំងរបស់អាជ្ញាធរមូលដ្ឋានមិនឲ្យមានការ វាស់វែងជាដើម។ រីឯនីតិវិធីដោះស្រាយបញ្ហាដីធ្លីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ អាជ្ញាធរដោះស្រាយវិវាទដីធ្លីថ្នាក់ជាតិ និង តុលាការនៅតែបន្តមានភាពយឺតយ៉ាវ និងមិនមានតម្លាភាពពេញលេញ។

### អនុសាសន៍ជាក់ជូនរដ្ឋាភិបាល៖

- ចុះបញ្ជីដីធ្លីជាប្រព័ន្ធសម្រាប់សហគមន៍ក្រីក្រនៅតាមបណ្តារាជធានី ខេត្ត និងពន្លឿនការផ្តល់កម្មវិធីដីធ្លីដល់ប្រជាពលរដ្ឋទាំងអស់នៅទូទាំងប្រទេស។
- រដ្ឋាភិបាលត្រូវដោះស្រាយបញ្ហាដីធ្លី ដែលនៅសល់ឲ្យបានចប់សព្វគ្រប់។

- រាល់ការដោះស្រាយទំនាស់ សូមកុំឲ្យមានការរើសអើង។
- បញ្ឈប់សកម្មភាពការឈូសឆាយ សាងសង់ ផ្សេងៗ លើដីជម្លោះដែលមិនទាន់មានដំណោះស្រាយ។
- ម្ចាស់ជំនួយត្រូវពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ មុននឹងផ្តល់ជំនួយដល់រដ្ឋាភិបាលក្នុងការអភិវឌ្ឍ
- ផ្តល់សំណងខូចខាត និងជំងឺចិត្តសមស្របដល់ប្រជាពលរដ្ឋរងគ្រោះ ឲ្យបានសមរម្យនិងយុត្តិធម៌
- សូមកុំប្រើប្រាស់កម្លាំងប្រដាប់អាវុធមកគំរាមគំហែងប្រជាពលរដ្ឋ
- ការអភិវឌ្ឍត្រូវផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋនៅនឹងកន្លែងដែលត្រូវអភិវឌ្ឍន៍។
- ធានាប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ ហើយគោរពសិទ្ធិមនុស្ស និងបញ្ឈប់ការប្រើប្រាស់ប្រព័ន្ធតុលាការមកគាបសង្កត់មកលើប្រជាពលរដ្ឋដែលទាមទារសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋានរបស់ខ្លួន។
- បញ្ឈប់ការរារាំងសកម្មភាពអហឹង្សារបស់ប្រជាពលរដ្ឋរងគ្រោះ ឧទាហរណ៍ ការដាក់ញត្តិស្នើសុំជាដើម។
- បន្តលុបចោលនូវសម្បទានណាដែលមិនគោរពតាមកិច្ចសន្យា និង ក្របខណ្ឌច្បាប់។
- ត្រូវធានាឲ្យបានថា អង្គការសង្គមស៊ីវិល អង្គការសហគមន៍មូលដ្ឋាន និងអ្នកស្រាវជ្រាវនានា មិនត្រូវបានរារាំងពីការចុះទៅប្រមូលព័ត៌មាន និងជួបប្រជុំដោយសេរី ជាមួយប្រជាជនកម្ពុជា ជាសាធារណៈ។
- បញ្ឈប់ការចោទប្រកាន់អង្គការសង្គមស៊ីវិលថាជាអ្នកញុះញង់នៅពីក្រោយប្រជាពលរដ្ឋ។

## ២).បញ្ហាជនជាតិដើមភាគតិច និងធនធានព្រៃឈើ

### សមិទ្ធផលរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលកំពុងតែរៀបចំ យុទ្ធសាស្ត្ររេដបូកជាតិដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលបណ្តាលមកពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ។ ក្នុងពេលថ្មីៗនេះរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការបង្កើនគម្របព្រៃឈើប្រទេសកម្ពុជាឲ្យបាន ៦០% នៃផ្ទៃដីប្រទេសត្រឹមឆ្នាំ២០៣០ តាមរយៈការអនុម័តសហគមន៍ព្រៃឈើឲ្យបាន ២លានហិកតា ដាក់តំបន់ការពារឲ្យបាន២.៨លានហិកតា ព្រៃការពារ៣លានហិកតា នៅក្នុងការរួមចំណែករបស់ប្រទេសកម្ពុជាក្នុងការអនុវត្តន៍អនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (INDCs) ។

តាមរយៈការអនុវត្តកន្លងមក សហគមន៍ជនជាតិដើមភាគតិច បានកត់សំគាល់ឃើញថា៖រាជ-រដ្ឋាភិបាល បាននឹងកំពុងយកចិត្តទុកដាក់ក្នុងការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច និងជំរុញកំណែទម្រង់អភិបាលកិច្ចដីធ្លី ធនធានធម្មជាតិ និងដោះស្រាយទំនាស់ដីធ្លីមួយចំនួន។ ជាក់ស្តែង គណៈកម្មការអន្តរក្រសួងបានដកហូតដីពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដែលមិនបានអនុវត្តត្រឹមត្រូវ

តាមច្បាប់ចំនួន៣៥ ក្នុងនោះមាន២៣ក្រុមហ៊ុន ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន[1] និង១២ក្រុមហ៊ុន ក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងចំណោម ៣០១ គម្រោង គិតត្រឹមខែតុលា ឆ្នាំ២០១៤[2] លើផ្ទៃដីសរុបប្រមាណ ២.២៨៩.៤៩០ហិចតា។ លើសពីនេះទៀត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បាននឹងកំពុងធ្វើសេចក្តីព្រាង "*សេចក្តីណែនាំស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីដែលត្រូវដាក់បញ្ចូលជាដីកម្មសិទ្ធិសមូហភាព ឬដែលត្រូវកាត់ចេញពីដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីជានីតិបុគ្គលរួច*" ក្នុងការធានាសុវត្ថិភាពដីធ្លី និងវប្បធម៌របស់ជនជាតិដើមភាគតិច។ លើសពីនេះទៀត រាជរដ្ឋាភិបាល បានជំរុញការអនុវត្តការទទួលស្គាល់សហគមន៍ព្រៃឈើ និងការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច ដូចជា បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីតំបន់ ព្រៃការពារ និង អភិរក្សជីវចំរុះព្រៃឡង់ ដែលស្ថិតនៅទីតាំងខេត្តចំនួន៤ មានខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង បានអនុម័តច្បាប់ អនុក្រឹត្យ និងគោលនយោបាយ ដើម្បីគាំទ្រដំណើរការ ចុះបញ្ជីដីសហគមន៍ និងបានចេញវិធានការការពារបណ្តោះអាសន្នដល់សហគមន៍មួយចំនួន និងបានផ្តល់ឱកាសឱ្យតំណាងសហគមន៍មួយចំនួន ចូលរួមកសាងផែនការវិនិយោគឃុំនិងមានផែនការចុះល្បាតទប់ស្កាត់បទល្មើសព្រៃឈើ ការបង្កើតឱ្យមានការចុះកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ បានផ្អាកការផ្តល់ដីសម្បទានសេដ្ឋកិច្ច រួមទាំងបានកាត់បន្ថយរយៈពេលសម្បទានដីមកត្រឹម៥០ឆ្នាំ ជាពិសេសក្រុមហ៊ុនមួយចំនួនបានផ្អាកការឈូសឆាយដីវិវាទនិងរង់ចាំការសិក្សាលំអិតជាក់ស្តែង ១៤សហគមន៍ក្នុងខេត្តរតនគិរី និងផ្អាកការសាងសង់ទំនប់វារីអគ្គីសនីនៅតំបន់ស្ទឹងឆាយអារ៉ែង។

**បញ្ហាប្រឈម និងសម្បទានដីសេដ្ឋកិច្ចៈ**

ប្រទេសកម្ពុជាមានគម្របព្រៃឈើប្រមាណ៥៧,៥៩%នៃផ្ទៃដីសរុបក្នុងឆ្នាំ២០១០ និងស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ។ ប្រជាជនដែលរស់នៅជិត និងជាប់ព្រៃឈើរស់នៅពឹងផ្អែកលើវិស័យព្រៃឈើ ដែលក្នុងនោះក៏មានជនជាតិដើមភាគតិចផងដែរ ដែលភាគច្រើនពួកគេរស់នៅពឹងផ្អែកលើព្រៃឈើសម្រាប់ជីវភាពប្រចាំថ្ងៃ និងផ្សារភ្ជាប់ទំនៀមទំលាប់ប្រពៃណីជាមួយនឹងព្រៃឈើផងដែរ ។

ទន្ទឹមនឹងសមិទ្ធផលដែលរដ្ឋាភិបាលបានដោះស្រាយខាងលើ យើងជាជនជាតិដើមភាគតិចបានមើលឃើញថានៅមានបញ្ហាប្រឈមមួយចំនួន ដែលកំពុងតែគំរាមកំហែងដល់សុវត្ថិភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីនិងធនធានធម្មជាតិ ដែលយើងកំពុងអាស្រ័យផលក្នុងការទ្រទ្រង់ដល់ជីវភាពរស់នៅប្រចាំថ្ងៃ និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការប្រមូលផ្តុំរបស់ជនជាតិដើមភាគតិច។

---

[1] យោងទិន្នន័យក្រសួងបរិស្ថាន

[2] គេហទំព័រ ទិន្នន័យពីការអភិវឌ្ឍ (http://www.opendevelopmentcambodia.net/company-profiles/economic-land-concessions/)

ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមួយចំនួន កំពុងបំពានលើក្របខណ្ឌច្បាប់ និងកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល ដោយបានរំលោភសិទ្ធិ វប្បធម៌ ប្រពៃណី ដី និងព្រៃឈើរបស់ជនជាតិដើមភាគតិច ដូចជាបានឈូសឆាយដីចំការវិលជុំ ព្រៃជំនឿ ព្រៃកប់សព ព្រៃបំរុង ការលុបអូរ ការឈូសឆាយព្រៃសងខាងមាត់អូរ បឹង ត្រពាំង ខឿនប្រសាទបុរាណ បាត់បង់ដើមច្បោះជ័រ បាត់បង់ប្រភពទឹក ដែនជម្រកសត្វព្រៃ។ល។ និងកាប់បំផ្លាញធនធានធម្មជាតិយ៉ាងសន្ធឹកសន្ធាប់។ បច្ចុប្បន្ននេះអាជ្ញាធរមួយចំនួនបានរារាំងដល់ដំណើរការចុះបញ្ជីដីសមូហភាព លើសពីនេះទៅទៀត ពួកគាត់បានឃុបឃិតជាមួយអ្នកមានអំណាចក្នុងការរំលោភដីធ្លី និងកាប់បំផ្លាញព្រៃឈើយ៉ាងអនាធិបតេយ្យ នៅក្នុងព្រៃសហគមន៍ និងតំបន់ព្រៃការពារ។ ជាពិសេសការបាត់បង់ព្រៃឈើដែលបណ្តាលមកពីការអភិវឌ្ឍគម្រោងខ្នាតធំ (រ៉ែ ទំនប់វារីអគ្គីសនី ឧស្សាហកម្មកសិកម្ម) ឧ. ការបាត់បង់ព្រៃឈើ៣ម៉ឺនហិកតាពីទំនប់វារីអគ្គីសនីសេសានក្រោម២។ បន្ថែមពីលើនេះទៀត ការអនុម័តសហគមន៍ព្រៃឈើ មានភាពយឺតយ៉ាវ និងមិនទាន់សម្រេចបានទៅតាមគោលដៅ ដែលបានកំណត់នាំឲ្យងាយរងគ្រោះចំពោះការរំលោភបំពាន និងបាត់បង់ព្រៃឈើ និងប៉ះពាល់ដល់ជីវភាពរស់នៅ។

គួយ៉ាងបញ្ហាប្រឈមធ្ងន់ធ្ងរ បានកើតមានឡើងនៅតាមតំបន់មួយចំនួនដូចខាងក្រោម៖

- វិវាទដីធ្លីរវាងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចជាមួយសហគមន៍ជនជាតិដើមភាគតិច មានដូចជាក្រុមហ៊ុន**ឡានហ្វេងនិងរ៉ូយហ្វេង** នៅឃុំប្រមេរ ឃុំសង្កែពីរ ខេត្តព្រះវិហារ និងក្រុមហ៊ុនប៊ិញហ្វឹក១ នៅឃុំស្រែព្រះ ខេត្តមណ្ឌលគិរី
- មិនមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋានអំពីផលប៉ះពាល់បរិស្ថាន និងសង្គមជាមុន និងមិនបានអនុវត្តតាមរូបមន្តស្បែកខ្លា ដូចជានៅឃុំប្រមេរ ឃុំសង្កែពីរ ខេត្តព្រះ-វិហារ ឃុំប៊ូស្រា ឃុំស្រែខ្ទុម ខេត្តមណ្ឌលគិរី
- មានការបញ្ចុះបញ្ចូលឱ្យសហគមន៍ជនជាតិដើមភាគតិចទទួលយកកម្មសិទ្ធិដីឯកជនតាមរយៈការអនុវត្តបទបញ្ជា០១ ករណីនេះកើតឡើងនៅ ឃុំត្រពាំងជោរ ខេត្តកំពង់ស្ពឺ ឃុំអន្លង់ជ្រៃ ខេត្តស្ទឹងត្រែង ឃុំប្រមេ ខេត្តព្រះវិហារ
- ដោយសារតែនៅមានទំនាស់ដីធ្លី និងភាពស្មុគស្មាញធ្វើផែនទីបឋម និងជាពិសេសដោយ មិនមានការដោះស្រាយពីអាជ្ញាធរមានសមត្ថកិច្ច បណ្តាលឱ្យការចុះបញ្ជីដី សមូហភាព សហគម-ន៍ជនជាតិដើមភាគតិចមានភាពយឺតយ៉ាវ
- ខ្វះការតាមដាន ត្រួតពិនិត្យ និងដំណោះស្រាយ ទៅលើទំនាស់វិវាទដីធ្លីពីស្ថាប័នមានសមត្ថ-កិច្ចចំពោះសហគមន៍ដែលទទួលបានប្លង់ដីសមូហភាពរួច
- ការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់សហគមន៍ជនជាតិដើមភាគតិច និងដែលស្ថិតនៅក្រៅតំបន់ដីសម្បទាន ហើយដឹកឈើចូលទៅក្នុងការដ្ឋានរបស់ក្រុមហ៊ុន ដូចជា នៅភូមិពូគង់ ឃុំស្រែព្រះ ភូមិចក់ចារ ឃុំស្រែឈូក ស្រុកកែវសីមា ខេត្តមណ្ឌលគិរី និងក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ ស្រុកសេសាន ខេត្តស្ទឹងត្រែង

- បំបិទសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំ និងការជួបជុំរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការប្រជុំនិងវគ្គបណ្តុះបណ្តាលនានា ដូចជាករណីប្រារព្ធទិវាជនជាតិដើភាគតិចឆ្នាំ២០១៥ នៅខេត្តមណ្ឌលគិរី ការបើកវគ្គបណ្តុះបណ្តាល និងប្រមូលផ្តុំ នៅស្រុកថ្មបាំង ខេត្តកោះកុង និងស្រុកឆែប ខេត្តព្រះវិហារ នៅភូមិចក់ចារ ខេត្តមណ្ឌលគិរី
- ឈ្មួញដែលមានអំណាច និងឋានៈ ការហូរចូលពីអ្នកចំណូលស្រុកនិងសហគមន៍ខ្លួនឯង កំពុងកាប់បំផ្លាញព្រៃឈើយកឈើលក់ និងដើម្បីយកដីជាកម្មសិទ្ធិផ្ទាល់ខ្លួន ដូចជានៅតំបន់ព្រៃឡង់ ស្រុកសំបូរ ខេត្តក្រចេះ
- ដោយសារតែក្រុមហ៊ុនបានឈូសឆាយដីស្រែ ចំការ និងព្រៃរកអនុផលព្រៃឈើ (ដូចជាជ័រវាំង ជ័រចុង និងជ័រទឹក) បានធ្វើឱ្យបាត់បង់មុខរបរ ខាតពេលវេលា កុមារមិនបានទៅសាលារៀន ជាពិសេសពាក់ព័ន្ធដល់សុវត្ថិភាពរបស់សហគមន៍ និងស្ត្រីដោយមានការគំរាមកំហែងពីអ្នកចំណូលស្រុក និងកម្មករក្រុមហ៊ុន និងបង្កអសន្តិសុខក្នុងសហគមន៍
- ក្រុមហ៊ុនរំលោភលើកិច្ចសន្យាជួលដីកសិកម្ម មិនគោរពលក្ខខ័ណ្ឌការងារ និងកេងប្រវ័ញ្ចកំលាំងពលកម្ម ដូចជាក្រុមហ៊ុនសូហ្វីន នៅប៊ូស្រា ខេត្តមណ្ឌលគិរី
- វិធានការការពារបណ្តោះអាសន្នដីសហគមន៍ជនជាតិដើមភាគតិចដែលរងចាំការចុះបញ្ជីដីចប់សព្វគ្រប់គឺមិនមានប្រសិទ្ធភាពក្នុងការទប់ស្កាត់បទល្មើសលក់ដី ទិញដីខុសច្បាប់ ដូចជាករណីនៅ ភូមិភ្នំវ៉ែ ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង
- ការចោទប្រកាន់និន្នាការនយោបាយ និងគម្រាមតាមចាប់សកម្មជនការពារដីធ្លី ករណីនេះកើតមាននៅភូមិប្រមេរ ខេត្តព្រះវិហារ និងឃុំជំនប់ ខេត្តកោះកុង
- ការផ្តល់សម្បទានដីសង្គមកិច្ចគឺបានប៉ះពាល់ដល់តំបន់ព្រៃផ្តល់ផល ព្រៃការពារ និងព្រៃជំនឿ ព្រៃកប់សព និងព្រៃបំរុងទុក និងជាពិសេសសុវត្ថិភាពរបស់សហគមន៍ជនជាតិដើមភាគតិច (ករណីនៅឃុំប៊ូស្រា ខេត្តមណ្ឌលគិរី ដែលតែងតែមានការគម្រាមកំហែងដេញកាប់ពីជនជាតិភាគតិច ចាម ទៅដល់ជនជាតិដើមភាគតិចពូនង។)

## អនុសាសន៍ដាក់ជូនរាជរដ្ឋាភិបាល:

១. សូមអោយរាជរដ្ឋាភិបាលពន្លឿនការចុះបញ្ជីដីសមូហភាពជនជាតិភាគតិចទាំង១៥ខេត្ត និងសហ-គមន៍ព្រៃឈើអោយបានឆាប់ ហើយបង្កើនចំនួន នៃការចុះបញ្ជីដីសមូហភាពពី១០ទៅ២៥សហ -គមន៍ក្នុងមួយឆ្នាំ។ ស្នើឱ្យក្រសួងរៀបចំដែនដី នគរបនីយកម្ម និងសំណង់ កំណត់ផែនការថវិកាអោយបានជាក់លាក់។

២. សូមអោយរាជរដ្ឋាភិបាលពន្លឿនការចេញវិធានការបណ្តោះអាសន្នស្តីពីការទប់ស្កាត់ការទិញ លក់ដីធ្លីសហគមន៍ ចំពោះសហគមន៍ដែលមានបំណងចុះបញ្ជីដីសមូហភាព គួរពិចារណាចេញវិធានការការពារបណ្តោះអាសន្នមុនរៀបចំបែបបទដាក់ពាក្យស្នើសុំចុះបញ្ជីដី។

៣. ពង្រឹងការអនុវត្តអនុក្រឹត្យ៨៣ (ដាក់ស្តែងការកំណត់ព្រំប្រទល់សហគមន៍មួយជាមួយសហគមន៍មួយទៀត)។
៤. សូមអោយរាជរដ្ឋាភិបាល ប្រកាន់ជំហរអព្យាក្រឹត្យ តម្លាភាព យុត្តិធ៌ម ក្នុងការតាមដាន ត្រួតពិនិត្យ និងដោះស្រាយបញ្ហាវិវាទដីធ្លីនិងព្រៃឈើ ដែលបានប៉ះពាល់ដីប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ដូចជាដីព្រៃកប់ខ្មោច ដីព្រៃអារក្ស ដីព្រៃបំរុងទុក ជាមួយនិងក្រុមហ៊ុន ឱ្យមានប្រសិទ្ធិភាពដើម្បីបញ្ចៀសការគម្រាមកំហែង ការបាត់បង់មុខរបរ និងបញ្ចៀសទំនាស់ដីធ្លីរ៉ាំរ៉ៃនៅក្នុងតំបន់សហគមន៍ជនជាតិដើមភាគតិច ដែលឈានអោយមានវិបត្តិសង្គមកាន់តែធ្ងន់ធ្ងរសំរាប់ប្រទេសកម្ពុជា។
៥.សូមអោយរាជរដ្ឋាភិបាលបន្តដកអាជ្ញាប័ណ្ណចំពោះក្រុមហ៊ុនណាដែលមិនគោរពកិច្ចសន្យា និងបន្តតាមដានត្រួតពិនិត្យចំពោះក្រុមហ៊ុនដែលបានលុបចោលរួច ដើម្បីធានាថាមិនមានសកម្មភាពបន្តប៉ះពាល់ដល់ដីសហគមន៍ជនជាតិដើមភាគតិច។
៦. រាជរដ្ឋាភិបាលត្រូវធានាថា មុនផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុន ត្រូវធានាថាមានការសិក្សាពីផលប៉ះពាល់បរិស្ថាន ពិគ្រោះយោបល់អោយបានពេញលេញ និងមានការព្រមព្រៀងជាមុន ជាមួយជនជាតិដើមភាគតិច។
៧. សូមអោយរាជរដ្ឋាភិបាលបញ្ឈប់ការលាបព៌ណនិន្នាការនយោបាយ ចាប់តំណាង និងការគំរាមកំហែងសហគមន៍ ក្នុងការជួបជុំដើម្បីស្វែងរកដំណោះស្រាយ បញ្ហាដីធ្លី និងព្រៃឈើ។
៨.គណៈកម្មការអន្តរក្រសួងបន្តយន្តការតាមដាន ត្រួតពិនិត្យរាល់ការដឹកឈើ និងកាប់ឈើខុសច្បាប់ពីតំបន់ការពារ តំបន់ព្រៃអភិរក្ស តំបន់ព្រៃកប់សព តំបន់ព្រៃឈើសហគមន៍ នាំចូលមកទីតាំងក្រុមហ៊ុន។
៩. ស្នើអោយអន្តរក្រសួងបែកចែកចំណាត់ថ្នាក់ប្រភេទព្រៃឈើ សំរាប់បង្កើតសហគមន៍ព្រៃឈើ ត្រូវគោរពតាមឆន្ទះរបស់ប្រជាពលរដ្ឋ និងច្បាប់។
១០.សូមអោយរដ្ឋាភិបាលជួយបញ្ជាក់ឈ្មោះប្រភេទជនជាតិនៅក្នុងអត្តសញ្ញាណប័ណ្ណដើម្បីងាយស្រួលក្នុងការកំណត់និងបញ្ជាក់អំពីប្រភេទជនជាតិដើមភាគតិចនីមួយៗ។
១១.សូមអោយរាជរដ្ឋាភិបាលគោរពសិទ្ធិសេរីភាព នៃការជួបជុំ ប្រមូលផ្តុំពិភាក្សាលើបញ្ហាសិទ្ធិដីធ្លី ព្រៃឈើ និងធនធានធម្មជាតិ នៅគ្រប់លំដាប់ថ្នាក់។
១២.លើកទឹកចិត្តអោយមានសមាសភាព ជនជាតិដើមភាគតិចមេភូមិ ឃុំស្រុក ខេត្ត និងដំណាងរាស្រ្តអោយបានច្រើន។
១៣.ស្នើអោយរាជរដ្ឋាភិបាល មោយៈភាពប្លង់កម្មសិទ្ធិឯកជនចំពោះសហគមន៍ដែលចុះបញ្ជី ដោយសារាចរ ០១ តាមវិធីមិនស្មុកស្មាញ និងមិនចំណាយថវិកា ដើម្បីទុកចុះបញ្ជីដីសមូហភាព។
១៤.ស្នើអោយរាជរដ្ឋាភិបាល ដាក់ទិវាជនជាតិដើមភាគតិចក្នុងប្រតិទិនប្រចាំឆ្នាំ
១៥.រៀបចំផែនការលើទឹកចិត្តក្នុងប្រព័ន្ធអប់រំដល់ជនជាតិដើមភាគតិច ចាប់ពីកំរិតថ្នាក់បឋម ដល់វិទ្យាល័យ។

១៦. ស្នើអោយរាជរដ្ឋាភិបាល គាំទ្រកសាងសមត្ថភាព និងសេវាសុខភាពដល់ស្ត្រីជនជាតិដើមភាគតិច។
១៧.ស្នើអោយជំរុញមានការគោរពការពារសុវត្ថិភាពសដល់ស្ត្រីជនជាតិដើមភាគតិច និងយកទុកចិត្តទុកដាក់កុមារដែលទៅជាម្តាយកធ្វើការងារក្រុមហ៊ុន
១៨. បញ្ឈប់កសាងទំនប់វារីអគ្គិសនីស្ទឹងឆាយអារ៉ែង ខេត្តកោះកុង
១៩. ពង្រឹកការផ្សព្វផ្សាយដល់ជនជាតិដើមភាគតិច
២០. សូមបង្ហាញរាល់សេចក្តីព្រាងអនុក្រឹត្យស្តីពីព្រៃការពារ រួមជាមួយនឹងការពិគ្រោះយោបល់ជាសាធារណៈជាមួយសហគមន៍ សង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា
២១.សូមដាក់បញ្ចូលតំបន់ព្រៃឡង់ក្នុងខេត្តទាំងបួន ជាតំបន់សហគ្រប់គ្រង ដោយផ្តល់ភាពស្របច្បាប់តាមរយៈការដាក់បញ្ចូលសិទ្ធិ និងតួនាទីរបស់បណ្តាញសហគមន៍ព្រៃឡង់ ក្នុងអនុក្រឹត្យឬលិខិតបទដ្ឋានគតិយុត្តណាមួយ
២២. ចុះស៊ើបអង្កេត និងចាត់វិធានការជាបន្ទាន់ចំពោះបទល្មើសព្រៃឈើ និងអាជីវកម្មឈើខុសច្បាប់នានា ជាពិសេសចំពោះបទល្មើសដែលពាក់ព័ន្ធនឹងអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
២៣. សូមរក្សាទុកតំបន់ព្រៃឈើដែលមានសក្តានុពលខ្ពស់ ដូចជាតំបន់ព្រៃឡង់ជាដើម ទុកជាតំបន់សិក្សាស្រាវជ្រាវអប់រំសម្រាប់បណ្តុះបណ្តាលធនធានមនុស្ស ក្នុងការលើកស្ទួយវិស័យអប់រំផ្នែកបរិស្ថាន ធនធានធម្មជាតិ និងអេកូទេសចរណ៍
២៤.បង្កើននូវកិច្ចសហប្រតិបត្តការរវាងក្រសួងពាក់ព័ន្ធក្នុងការធ្វើផែនការគ្រប់គ្រងនិងការប្រើប្រាស់ដីព្រមទាំងរវាង រដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីដោះស្រាយបញ្ហាព្រៃឈើ និងបញ្ហាព្រំប្រទល់ដីសហគមន៍និង ដីសម្បទានសេដ្ឋកិច្ច។
២៥. សូមអោយរាជរដ្ឋាភិបាលពន្លឿននូវការអនុម័តសហគមន៍ព្រៃឈើ និងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើនិងមានកញ្ចប់ថវិកាជាតិបន្ថែម ដើម្បីឆ្លើយតបទៅនឹងការតាំងចិត្តក្នុងការបង្កើនគម្របព្រៃឈើប្រទេសកម្ពុជាឲ្យបាន ៦០% នៃផ្ទៃដីប្រទេសត្រឹមឆ្នាំ២០៣០ ។

## ៣). បញ្ហាទំនប់វារីអគ្គីសនី

### សមិទ្ធផលរបស់រាជរដ្ឋាភិបាល

ដើម្បីឆ្លើយតបទៅនឹងបញ្ហាទំនប់វារីអគ្គីសនី រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើសេចក្តីព្រាងច្បាប់មួយចំនួនដូចជាសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ល។ ក្នុងនោះដែររដ្ឋសភាក៏បានអញ្ជើញរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពលដើម្បីធ្វើការស្រាយបំភ្លឺពាក់ព័ន្ធនឹងការអនុវត្តគម្រោងទំនប់វារីអគ្គីសនី[3] ព្រមទាំងចុះទៅដល់តំបន់គម្រោងផ្ទាល់ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីទស្សនៈរបស់សហគមន៍ទាក់ទងនឹងគម្រោងសាងសង់ទំនប់វារីអគ្គីសនីសេសានក្រោម២។ ថ្មីៗនេះ

[3] គម្រោងវារីអគ្គីសនីសេសានក្រោម២

រាជរដ្ឋាភិបាលកម្ពុជាជាពិសេស ក្រសួងរ៉ែ និងថាមពលក៏បានអនុញ្ញាត្តិឲ្យតំណាងសហគមន៍ និងតំណាងអង្គការសង្គមស៊ីវិលចូលជួបពិភាក្សាពីគម្រោងទំនប់វារីអគ្គីសនីសេសានក្រោម២នេះ ហើយក៏បានចូលរួមសហការជាមួយអង្គការសង្គមស៊ីវិល (សម្ព័ន្ធទន្លេកម្ពុជា)ដើម្បីរៀបចំទស្សនកិច្ចសិក្សា និងវេទិកាសាធារណៈដើម្បីប្រមូលនូវកង្វល់របស់សហគមន៍ដែលរងផលប៉ះពាល់ពីគម្រោងទំនប់វារីអគ្គីសនីសេសានក្រោម២នេះមកពិចារណា និងរកដំណោះស្រាយ។

## បញ្ហាប្រឈម

វិស័យទំនប់វារីអគ្គីសនីនៅក្នុងប្រទេសកម្ពុជាគឺជាវិស័យមួយដែលរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុង ធ្វើការអភិវឌ្ឍដើម្បីជាតំរូវការដល់ប្រជាពលរដ្ឋ និងជាប្រភពប្រាក់ចំណូលដើម្បីធ្វើការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិ ប៉ុន្តែប្រទេសកម្ពុជានៅមិនទាន់បានត្រៀមខ្លួនដើម្បីធ្វើការអភិវឌ្ឍវិស័យនេះឲ្យបានពេញលេញនៅឡើយទេ។ តាមការសង្កេតឃើញថា ការអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជានៅមានកម្រិតនៅឡើយដែលជាហេតុបណ្តាលឲ្យវិស័យមួយនេះមានការលំបាកក្នុងការគ្រប់គ្រងថវិកាដ៏ច្រើនសន្ធឹកសន្ធាប់នេះ។ ផ្ទុយទៅវិញ គម្រោងសាងសង់ទំនប់វារីអគ្គីសនីបានបណ្តាលឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរជាអវិជ្ជមានទៅលើបរិស្ថាន សង្គម វប្បធម៌ និងដីព្រៃសហគមន៍ជនជាតិដើមភាគតិចតាមរយៈការកាប់បំផ្លាញព្រៃឈើ ជីកយករ៉ែ ជាមួយនិងការបាត់បង់ គុណភាពទឹកនិង គុណភាពដីកសិកម្ម សុខភាពមនុស្ស និងសត្វ។ ព្រៃឈើត្រូវបានកាប់បំផ្លាញទាំងក្នុង និងក្រៅបាតអាងនៃគម្រោងទំនប់វារីអគ្គីសនីដែលនាំឲ្យបាត់បង់ជំរករបស់សត្វព្រៃ[4]។ ការបាត់បង់លំនៅឋាន ដីស្រែចំការ[5] តាមរយៈគម្រោងសាងសង់ទំនប់វារីអគ្គីសនីត្រូវបានក្រុមហ៊ុនវិនិយោគគម្រោងសាងសង់ទំនប់វារីអគ្គីសនីរឹបអូសយកពីប្រជាពលរដ្ឋយ៉ាងអយុត្តិធម៌។ ជាងនេះទៅទៀត គ្រប់គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គីសនីទាំងអស់នៅក្នុងប្រទេសកម្ពុជាគឺសហគមន៍មិនដែលបានទទួលព័ត៌មាន និងមិនដែលបានចូលរួមពិគ្រោះយោបល់ឲ្យបានពេញលេញជាមុននោះទេ ដើម្បីធ្វើសេចក្តីសំរេចចិត្តក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គីសនីទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលជាហេតុនាំឲ្យមានការរំលោភសិទ្ធិមនុស្ស និងការជម្លៀសប្រជាពលរដ្ឋចេញពីតំបន់ដែលក្រុមហ៊ុនវិនិយោគគម្រោងសាងសង់ទំនប់វារីអគ្គីសនីដោយបង្ខំ។

## អនុសាសន៍សំរាប់ជាក់ជូនរាជរដ្ឋាភិបាលៈ

១.ពង្រឹង និងពិនិត្យមើលការអភិវឌ្ឍរបស់ក្រុមហ៊ុនវិនិយោគទំនប់វារីអគ្គិសនីដើម្បីធានាថាក្រុមហ៊ុនទាំងនោះគោរពច្បាប់ និងគោលការណ៍ផ្សេងៗ។

២. បង្កើតវេទិកាពិភាក្សារវាងសហគមន៍ និងក្រុមហ៊ុនដើម្បីចរចារទាក់ទងនឹងការបែងចែកផលប្រយោជន៍រវាងអ្នករងផលប៉ះពាល់ និងអ្នកដែលទទួលផលចំណេញពីការអភិវឌ្ឍទំនប់វារីអគ្គិសនី

[4] សត្វក្រពើភ្នំ និងត្រីនាគនៅតំបន់អារ៉ែង

[5] គម្រោងវារីអគ្គីសនីសេសានក្រោម២

ត្រូវជានាថាដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវមានការចូលរួមពេញលេញ ពីសាធារណៈជន ជាពិសេសគឺសហគមន៍ដែលទទួលរងផលប៉ះពាល់ពីការអភិវឌ្ឍគម្រោងសាងសង់ទំនប់វារីអគ្គិស-នី។

៣. បញ្ឈប់រាល់គម្រោងសាងសង់ទំនប់វារីអគ្គិសនីទាំងឡាយណាដែលមានផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសង្គម។

៤. ត្រូវជានាថាព័ត៌មានគម្រោងសាងសង់ទំនប់វារីអគ្គិសនី ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងដែលជាព័ត៌មានពិតដល់សហគមន៍ដែលទទួលរងផលប៉ះពាល់ពីគម្រោងសាងសង់ទំនប់វារីអគ្គិសនី និងគោរពសិទ្ធិមនុស្ស។

## ៤). បញ្ហាសិទ្ធិទទួលបានព័ត៌មាន

### សមិទ្ធផលរបស់រាជរដ្ឋាភិបាល

បច្ចុប្បន្ន រាជរដ្ឋាភិបាលបានប្តេជ្ញាជាចំហ និងកំពុងដំណើរការធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ក្រោមការដឹកនាំដោយក្រសួងព័ត៌មាន និងបើកចំហឲ្យមានការចូលរួមពីបណ្តាភាគីពាក់ព័ន្ធ ក្នុងនោះមានសង្គមស៊ីវិលផងដែរ។ ក្នុងកំឡុងពេលថ្មីៗនេះ អនុគណៈកម្មការធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានរបស់ក្រសួងព័ត៌មាន បានតាក់តែងសេចក្តីព្រាងច្បាប់ទី១ចប់ហើយ និងបានផ្តល់ នូវជំពូកចំនួន ៤ ដែលមាន ២០មាត្រា ចែករំលែកជូនសង្គមស៊ីវិលសម្រាប់ធ្វើការចូលរួមមតិ យោបល់ក្នុងការកែលម្អ។ កិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសតាក់តែងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានមានលក្ខណៈបើកចំហក្នុងការពិភាក្សា និងស្វាគមន៍ចំពោះការចូលរួម និងធាតុចូលវិជ្ជមានទាំងអស់ពីសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងក្រសួងពាក់ព័ន្ធនានា។

ដើម្បីចូលរួមចំណែកក្នុងការផ្តល់មតិយោបល់ និងធានាបានថា ព្រះរាជាណាចក្រកម្ពុជាយើងនឹងមានច្បាប់ដ៏ល្អមួយស្តីពីសិទ្ធិទទួលព័ត៌មានដែលបម្រើផលប្រយោជន៍ទូទៅ ក្រុមអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋានយើងខ្ញុំ ទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដែលធ្វើការងារទាក់ទងនឹងវិស័យបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ បានជួបពិភាក្សាគ្នា និងបានឯកភាពគ្នាដាក់ជូនគណៈកម្មការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននូវ ប្រភេទព័ត៌មានមួយចំនួនដែលយើងខ្ញុំយល់ថាជាតម្រូវការចាំបាច់ ត្រូវពិចារណាដាក់បញ្ចូលនៅក្នុងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។

### បញ្ហាប្រឈម

ប្រជាពលរដ្ឋមានតួនាទីពេញលេញក្នុងការប្រាស្រ័យផល និងការពារនូវរាល់ធនធានធម្មជាតិ និងបរិស្ថាន ហើយបច្ចុប្បន្នយើងមើលឃើញថាប្រជាពលរដ្ឋទូទៅ ជាពិសេសសហគមន៍ ទទួលបានមិនគ្រប់គ្រាន់ ឬ ខ្វះខាតនូវព័ត៌មានជាច្រើនទាក់ទងជាពិសេសនឹងវិស័យបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសជំណោះស្រាយនានាពីអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នតុលាការ ។ម្យ៉ាងទៀតតាមការសិក្សា និងវិភាគឃើញថាមូលដ្ឋានច្បាប់នាពេលបច្ចុប្បន្ន និងការអនុវត្តន៍ នៅមាន

ការខ្វះខាតភាគច្រើនទាក់ទងនឹងវិស័យបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ហើយមកទល់ពេលនេះ ប្រទេសកម្ពុជាកំពុងនៅមានបញ្ហាប្រឈមសំខាន់ៗបួន ដែលរារាំងប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន។ បញ្ហាប្រឈមទាំងនេះ រួមមាន: ១. ការអនុវត្តនូវការបង្ហាញព័ត៌មានរបស់រាជរដ្ឋាភិបាលនៅទន់ខ្សោយ, ២. ប្រជាពលរដ្ឋ មិនបានទទួលដំណឹងអំពីសិទ្ធិទទួលព័ត៌មាន ហើយទាមទារឲ្យមានឯកសារមួយចំនួនដើម្បីបង្ហាញ, ៣. មន្ត្រីរដ្ឋាភិបាល យល់មិនច្បាស់អំពីទស្សនៈទានជាមូលដ្ឋាននៃសិទ្ធិទទួលព័ត៌មាន, ៤. ក្រុមអាជ្ញាធររដ្ឋាភិបាល មានភាពស្ទាក់ស្ទើរក្នុងការបង្ហាញព័ត៌មានដែលពាក់ព័ន្ធនឹងបញ្ហានានាដែលពួកគេចាត់ទុកថា ជាចំណុចរសើបផ្នែកនយោបាយ ។

**ប្រភេទព័ត៌មានពាក់ព័ន្ធនឹងវិស័យគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានដែលបច្ចុប្បន្នកំពុងត្រូវការ ៖**

- ច្បាប់ស្តីពីព្រៃឈើ និងអនុក្រឹត្យស្តីពីព្រៃ និងដីសម្បទានសេដ្ឋកិច្ច និងសង្គមកិច្ច ច្បាប់អស្សាមិករណ៍ ច្បាប់ភូមិបាល ច្បាប់សម្បទានដីសេដ្ឋកិច្ច ផែនការមេរបស់រដ្ឋ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការវិនិយោគ និង ប៉ះពាល់ដល់បញ្ហាដីធ្លី។ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងនឹងវិស័យឧស្សាហកម្ម និស្សារណកម្ម។ អនុក្រឹត្យស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន។
- របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម (EIA)
- ព័ត៌មានអំពី ទំហំដីអតិបរមាដែលប្រជាជនម្នាក់ៗមានសិទ្ធិជាម្ចាស់ និងព្រំប្រទល់ព្រៃ(ទំហំដីសហគមន៍ និងដីតំបន់ការពារ/អភិរក្ស - ទំហំដីដែលគ្រប់គ្រងដោយសហគមន៍ និងដីដែលគ្រប់គ្រងដោយក្រុមហ៊ុន)។ ឯកសារ ឬ ព័ត៌មានអំពី របៀបអាស្រ័យផលពីអនុផលព្រៃឈើ និងអត្ថប្រយោជន៍យូរអង្វែង។
- ទីតាំងនិងទំហំដីព្រៃសម្បទានសេដ្ឋកិច្ច និងសង្គមកិច្ចទូទាំងប្រទេស និងចំណូលដែលបានពីព្រៃសម្បទាន និងការចំណាយរបស់រដ្ឋាភិបាលចំពោះចំណូលនោះ។ ក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណ ឈ្មោះ អាស័យដ្ឋាន ម្ចាស់ភាគហ៊ុន ឯកសារដេញថ្លៃ លិខិតអនុញ្ញាតិ និងកិច្ចសន្យាក្រុមហ៊ុន ជាមួយរដ្ឋាភិបាល ។ ព័ត៌មានអំពីសំណងសមរម្យចំពោះផលប៉ះពាល់ដល់ប្រជាពលរដ្ឋតាមតម្លៃទីផ្សារ គោលការណ៍ និងពេលវេលានៃការបណ្តេញចេញ ម្យ៉ាងទៀតត្រូវបង្ហាញអំពីទោសទណ្ឌចំពោះករណីរំលោភ ឬ មិនអនុវត្តកិច្ចសន្យា។
- ព័ត៌មានអស្សាមិករណ៍រួមបញ្ចូលទាំងសំណង និងការតាំងលំនៅថ្មីរបស់សហគមន៍ ហេដ្ឋារចនាសម្ព័ន្ធថ្មី និងអ្នកដែលទទួលខុសត្រូវសំណង(រដ្ឋាភិបាល ឬ ក្រុមហ៊ុន)
- ព័ត៌មានអំពីតំបន់រ៉ែ ការសិក្សាស្រាវជ្រាវធនធានរ៉ែ ចំណូលចំណាយពាក់ព័ន្ធនឹងវិស័យរ៉ែ
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងនឹងវិស័យជលផល ប្រភេទឧបករណ៍នេសាទដែលបានកំណត់។

- ថវិកាជាតិគាំទ្រការអភិវឌ្ឍ ក្នុងវិស័យ ដីធ្លី ព្រៃឈើ ជលផល និងរ៉ែ។ ផែនការគម្រោងអភិវឌ្ឍបឹងទន្លេសាប ផែនការគ្រប់គ្រងព្រៃលិចទឹក ផែនការគម្រោងអភិវឌ្ឍទំនប់វារីអគ្គិសនី។ ការវិវត្តន៍របស់សហគមន៍នេសាទ និងការអភិវឌ្ឍគោលនយោបាយទាក់ទងនឹងវិស័យជលផល។
- ទំហំតំបន់អភិរក្សធនធានជលផល ទិន្នន័យនាំត្រីចេញ និងនាំត្រីចូល និងរបាយការណ៍បទល្មើស និងបញ្ជីឈ្មោះជនល្មើសដោយរួមបញ្ចូលទាំងគ្រប់ភាគីពាក់ព័ន្ធ។
- ឯកសារស្តីពី ដំណោះស្រាយ ចំណាត់ការ និង លទ្ធផល នៃសេចក្តីសម្រេចណាមួយពីអាជ្ញាធរមានសមត្ថកិច្ច ឬ ស្ថាប័នតុលាការ។

## អនុសាសន៍សម្រាប់រាជរដ្ឋាភិបាល

- បង្កើតអោយមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដែលជាច្បាប់មួយដ៏សំខាន់ សម្រាប់ប្រទេស។ ក្នុងច្បាប់នេះគួរមានចែងកំណត់អោយស្ថាប័នមានសមត្ថកិច្ច ត្រូវឆ្លើយតប ទៅនឹងការសួរព័ត៌មានដូចច្បាប់ភូមិបាល (មាត្រា២៤០ កំណត់ឲ្យរដ្ឋបាលសុរិយោដី ឆ្លើយតបទៅនឹងការសួរព័ត៌មានសុរិយោដីពីជនដែលមានការទាក់ទងទាំងអស់) ហើយគួរមានចែងដូច (មាត្រា ១៦ច្បាប់ស្តីពីអស្សាមិករណ៍ តម្រូវឲ្យមានការពិគ្រោះយោបល់ ជាសាធារណៈ (នៅក្នុងកម្រិតជាអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំសង្កាត់ និងតំណាងភូមិ ឬសហគមន៍)។
- កំណត់ពេលវេលា នីតិវិធីបណ្តឹងឱ្យបានច្បាស់លាស់ និងបង្កើតទីប្រឹក្សាប្រជាពលរដ្ឋដែលជួយសម្រួលដល់បណ្តឹងរបស់ប្រជាពលរដ្ឋ និងមានយន្តការតាមដានត្រួតពិនិត្យ។ ដំណោះស្រាយបណ្តឹងផ្អែកលើគោលការណ៍ច្បាប់ដែលមានជាធរមាន ហើយលទ្ធផលនៃការដោះស្រាយត្រូវអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ។
- ក្រសួងព័ត៌មានគួរជំរុញច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានឱ្យបានមុនដំណាច់ឆ្នាំ ២០១៦ ដោយមានការចូលរួមមតិយោបល់ពីសង្គមស៊ីវិល និង ប្រជាពលរដ្ឋ។
- បង្កើតស្ថាប័នជាតិ/ស្នងការព័ត៌មាន ឬ កំណត់អ្នកទទួលខុសត្រូវនៅតាមស្ថាប័នពាក់ព័ន្ធនានាក្នុងការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ។
- ស្ថាប័នសាធារណៈត្រូវបង្កើនការផ្សព្វផ្សាយគ្រប់រូបភាព រួមទាំងបណ្តាញសង្គម វិទ្យុ ទូរទស្សន៍ មេភូមិ/មេឃុំ ផ្ទាំងប៉ាណូ វេទិកាសហគមន៍ និងព្រឹត្តិការណ៍ជាតិផ្សេងៗ។ ព័ត៌មានអំពីការអភិវឌ្ឍន៍ត្រូវផ្សព្វផ្សាយជាសារធារណៈ មុននឹងក្រុមហ៊ុនឯកជន ឬរដ្ឋចាប់ផ្តើមដំណើរការក្នុងរយៈពេលមួយសមស្រប។ ការផ្សព្វផ្សាយត្រូវផ្សារភ្ជាប់នឹងការតាមដាន និង ការដាក់ពិន័យ ប្រសិនបើធ្វេសប្រហែស មិនបានធ្វើតាមច្បាប់កំណត់។
- បង្កើត/បង្កើនភាពជាដៃគូក្នុងការផ្តល់ព័ត៌មានពេញលេញរវាង ប្រជាពលរដ្ឋ អង្គការសហគមន៍មូលដ្ឋាន សង្គមស៊ីវិល និងស្ថាប័នរដ្ឋ។ ម្យ៉ាងទៀតត្រូវមានកញ្ចប់ថវិកាសម្រាប់ជួយទ្រទ្រង់សកម្មភាពរបស់សហគមន៍មូលដ្ឋាន។

- អនុក្រឹត្យ បង្កើតអោយមានគណៈកម្មការជំនាញ ដោះស្រាយ និងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមទាំង សង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន។
- អនុវត្តអនុក្រឹត្យស្តីអំពីការផ្តល់សម្បទានអាជីវកម្មធនធានរ៉ែ (ដែលមានចែងលក្ខខណ្ឌមុននឹងអនុវត្តគំពោង ត្រូវតែពិគ្រោះយោបល់ជាសាធារណៈជាមួយប្រជាពលរដ្ឋដើម្បីបញ្ចៀសការប៉ះពាល់បរិស្ថាន និងសង្គម)។ អនុក្រឹត្យបង្កើតគណៈកម្មការបច្ចេកទេស ឬនីតិវិធីដើម្បីអនុវត្ត/ជូនដំណឹងអំពីសេចក្តីសម្រេច អស្សាមិករណ៍ និងផ្តល់សំណងដល់ម្ចាស់មុននឹងធ្វើអស្សាមិករណ៍។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងផ្តោត និងធានាបាននូវការផ្តល់នូវប្រភេទព័ត៌មានត្រូវការទាំងឡាយដែលពាក់ព័ន្ធក្នុងវិស័យគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានក៏ដូចជាអនុសាសន៍ខាងលើ ដើម្បីធានាថាស្ថាប័នសាធារណៈពាក់ព័ន្ធនឹងចាត់វិធានការច្បាប់ក៏ដូចជាវិធានការរដ្ឋបាលឱ្យបានសមស្រប និងទាន់សភាពការណ៍ ព្រមទាំងធានាថាប្រជាជនកម្ពុជាអាចអនុវត្តបាននូវសិទ្ធិទទួលបានព័ត៌មានពេញលេញ។

## ៥).វិស័យឧស្សាហកម្មនិស្សារណកម្ម

### បញ្ហាប្រឈម

ឧស្សាហកម្មនិស្សារណកម្ម ជាវិស័យដ៏សំខាន់មួយដែលរួមចំណែកនៅក្នុងចំណូលថវិកាជាតិ និងអភិវឌ្ឍន៍កិច្ចជាតិ។ បច្ចុប្បន្ន ជាង ១០០ ក្រុមហ៊ុនជាតិ និងអន្តរជាតិ ត្រូវបានផ្តល់អាជ្ញាប័ណ្ណរុករក និងអាជីវកម្មធនធានរ៉ែ នៅក្នុង ១៨ខេត្តក្រុង នៃព្រះរាជាណាចក្រកម្ពុជា។ ការអនុវត្ត-នូវក្របខណ្ឌច្បាប់ និងបច្ចេកទេសដែលទាក់ទងនឹងវិស័យនេះ នៅមិនទាន់ធានាឱ្យបានការគ្រប់គ្រងមួយដោយមានការទទួលខុសត្រូវលើសង្គម សេដ្ឋកិច្ច និងបរិស្ថាននៅឡើយ។ បច្ចុប្បន្ន ប្រតិបត្តិការសិក្សាស្រាវជ្រាវ និងអាជីវកម្មរ៉ែ បាននិងកំពុងបង្កផលប៉ះពាល់ជាអវិជ្ជមាន ទៅដល់សហគមន៍និងបរិស្ថាន។ ការប្រើប្រាស់សារធាតុគីមី បានប៉ះពាល់គុណភាពទឹក-ដី សុខភាពមនុស្ស និងសត្វ។ ក្រុមហ៊ុនខ្លះមិនបានលុបរណ្តៅដែលក្រុមហ៊ុនបានជីកយករ៉ែ ហើយបង្កគ្រោះថ្នាក់ដល់សត្វពាហនៈ និងជីវិតមនុស្សផងដែរ។ ក្រុមហ៊ុនមិនបានពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ផ្ទាល់ ពីប្រតិបត្តិការរបស់ខ្លួនឡើយ។ កង្វះព័តមាន និងការចូលរួមជាសាធារណៈបែបនេះ កាន់តែធ្វើឱ្យសហគមន៍មានការព្រួយបារម្ភ និងកង្វល់ពីផលប៉ះពាល់ និងជីវភាពរស់នៅរបស់ពួកគាត់។ បញ្ហាដីធ្លី សំណង និងការផ្លាស់ប្តូរទីលំនៅ ជាបញ្ហាប្រឈមចំបងរបស់សហគមន៍ ជាពិសេស ជនជាតិដើមភាគតិច។ ក្រុមហ៊ុនមិនបានគោរពសិទ្ធិនិងទំនៀមទំលាប់របស់ជនជាតិដើមភាគតិច ដោយធ្វើប្រតិបត្តិការរុករករ៉ែនៅតាមព្រៃតំណម ព្រៃអារក្ស ដោយមិនបានពិភាក្សានិងផ្តល់ដំណឹងជាមុន។ ម្យ៉ាងវិញទៀត នេះក៏ផ្តល់ឱកាសដល់ឯកជន និងក្រុមហ៊ុនមួយចំនួន ឆ្លៀតឱកាសធ្វើសកម្មភាពរុករកនិងអាជីវកម្មរ៉ែ មិនស្របច្បាប់។ សហគមន៍មិនបានទទួលព័តមានគ្រប់គ្រាន់ និងការពិគ្រោះយោបល់ពេញលេញ មុននឹង

មានការធ្វើសេចក្តីសម្រេចចិត្តលើគម្រោងរុករក និងអភិវឌ្ឍន៍ធនធានរ៉ែ នៅក្នុងតំបន់ដែលពួកគាត់កំពុងរស់នៅ ។

## សមិទ្ធផលរបស់រាជរដ្ឋាភិបាល

យោងតាមក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(២០១៤-២០១៨) សម្រាប់វិស័យរ៉ែ ប្រេងកាត និងឧស្ម័ន រដ្ឋាភិបាលកំពុងធ្វើការជម្រុញប្រែក្លាយវិស័យនេះ ឱ្យទៅជាអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមមួយសម្រាប់ប្រទេសកម្ពុជា ដែលរួមចំណែកឱ្យមានការបង្កើតនូវក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិសំខាន់ៗ ដើម្បីគ្រប់គ្រងវិស័យនេះ។ ទាំងនេះអាចជម្រុញការចូលរួម និងការពិគ្រោះយោបល់ដ៏ពេញលេញ ជាមួយសហគមន៍ទទួលរងផលប៉ះពាល់ផងដែរ។ ស្របគ្នានេះដែរ រដ្ឋាភិបាល ក៏បានជម្រុញ ឱ្យមានការ ចូលរួមអភិវឌ្ឍន៍នៅក្នុងតំបន់ពីក្រុមហ៊ុន តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធមួយចំនួននៅក្បែរ និងនៅតាមតំបន់អាជីវកម្មរ៉ែ។ ប៉ុន្តែការទទួលបានព័តមាននិងកិច្ចអន្តរាគមន៍ទៅលើបញ្ហារបស់សហគមន៍ រងផលប៉ះពាល់ នៅថ្នាក់មូលដ្ឋាននៅមានកម្រិតនៅឡើយ។

## អនុសាសន៍ជាក់ជូនរាជរដ្ឋាភិបាល

១. មាន និងអនុវត្តនូវការពិគ្រោះយោបល់ និងការចូលរួមជាសាធារណៈ ក្នុងរយៈពេលគ្រប់គ្រាន់ នៅក្នុងដំណាក់កាលរុករក ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងដំណាក់កាលធ្វើអាជីវកម្មធនធានរ៉ែ

២. ការពារសិទ្ធិរបស់សហគមន៍រងផលប៉ះពាល់ និងជនជាតិដើមភាគតិច នៅក្នុងការចូលរួមពិគ្រោះយោបល់ ដោយអនុវត្តនូវគោលការណ៍ព្រមព្រៀងដោយសេរី ជាមុន និងទទួលបានព័តមាន (FPIC)

៣. តម្រូវ និងជម្រុញឱ្យក្រុមហ៊ុនអនុវត្ត និងគោរពទៅតាមច្បាប់ សម្រាប់ប្រតិបត្តិការសិក្សាស្រាវជ្រាវ និងអាជីវកម្មរ៉ែ ប្រេងកាត និងឧស្ម័នរបស់ក្រុមហ៊ុន ព្រមទាំងតាមដានសកម្មភាពក្រុមហ៊ុនឱ្យបានទៀងទាត់

៤. គាំទ្រ និងសម្របសម្រួលឱ្យមានយន្តការពហុភាគី ក្នុងការដោះស្រាយផលប៉ះពាល់ និងសំណងសមរម្យដែលសហគមន៍ព្រមព្រៀង និងទទួលយកបាន

៥. ប្រើប្រាស់យន្តការផ្លាស់ប្តូរទីលំនៅថ្មី ជាមធ្យោបាយចុងក្រោយ សម្រាប់ដោះស្រាយបញ្ហាផលប៉ះពាល់បរិស្ថាន និងសង្គម

៦. បម្រុងទុកថវិកាពីចំណូលធនធានរ៉ែ ប្រេងកាតនិងឧស្ម័ន សម្រាប់អភិវឌ្ឍសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់

៧. ជម្រុញឱ្យក្រុមហ៊ុនគិតគូរ និងផ្តល់នូវជម្រើសមុខរបរដែលអាចបាត់បង់ ដោយសារប្រតិបត្តិការរុករក ស្រាវជ្រាវ និងអាជីវកម្មរ៉ែ ប្រេងកាត និងឧស្ម័ន

៨. បើកចំហរ និងផ្សព្វផ្សាយព័តមានដែលទាក់ទងនឹងប្រតិបត្តិគម្រោងការរុករក ស្រាវជ្រាវ និងអាជីវកម្មរ៉ែ ប្រេងកាត និងឧស្ម័ន ដល់សហគមន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

## សម្រាប់វិស័យឯកជន

១យោបល់ និងការចូលរួមជាសាធារណៈ ជាមួយមានផែនការច្បាស់លាស់ ក្នុងការពិគ្រោះ . សហគមន៍រងផលប៉ះពាល់ សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

២ផ្តល់ដំណឹង និងព័តមានជា .មុន ព្រមទាំងឯកសារដែលពាក់ព័ន្ធ ជាមួយសហគមន៍ ពីប្រតិបត្តិការ និងផែនការសកម្មភាពរុករក ស្រាវជ្រាវ និងអាជីវកម្មរ៉ែ ប្រេងកាត និងឧស្ម័ន

៣ .ផ្តល់ឱកាសការងារ និងការកសាងសមត្ថភាពបច្ចេកទេស សម្រាប់សហគមន៍មូលដ្ឋាន ដើម្បីអាចជាជម្រើសជីវភាពថ្មី

៤ .គោរពលក្ខខណ្ឌការងារ ដែលបានព្រមព្រៀង និងសិទ្ធិរបស់សហគមន៍រងផលប៉ះពាល់ និងជនជាតិដើមភាគតិច

៥ .និងច្បាស់លាស់ ឧ អនុវត្ត និងគោរពទៅតាមផែនការគ្រប់គ្រងបរិស្ថាន និងសង្គមឱ្យបានត្រឹមត្រូវ . លុបបំពេញរណ្តៅដែលបានជីក ឬខួង

៦ (យន្តការពហុភាគី) ដោះស្រាយរាល់បញ្ហាដែលកើតមានឡើងជាមួយសហគមន៍ ដោយសន្តិវិធី . និងផ្តល់នូវដំណោះស្រាយដែលអាចទទួលយកបាន

## ៦). ការវិនិយោគប្រកបដោយការទទួលខុសត្រូវ

វិស័យឯកជនត្រូវបានគេចាត់ទុកជាកំលាំងចលករនៃកំណើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។ ការកើតមាននៃវិស័យឯកជនទាំងនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកំពស់ កំណើន ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងការបង្កើតការងារ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ។ អស់រយៈពេលជាច្រើនទសវត្សន៍ វិស័យឯកជនបានចូលរួមចំណែក និងចូលរួមជាមួយវិស័យជាច្រើន ហើយប្រការនេះនឹងបង្កើតឲ្យមាននូវលក្ខខណ្ឌអំណោយផលពីភាគីពាក់ព័ន្ធ។

ការអនុវត្តរបស់វិស័យឯកជន ទាមទារឲ្យអាជីវកម្មរបស់ខ្លួនគោរពសិទ្ធិមនុស្ស។ ការពន្លឿនវិនិយោគក្នុងប្រទេសកម្ពុជាដោយមិនគិតគូរពីអភិបាលកិច្ចល្អ ដោយរួមមាន តម្លាភាព គណនេយ្យភាព និតិរដ្ឋ និងការទទួលបានយុត្តិធម៌ នាំឲ្យមានការពង្រីកការអនុវត្តសាជីវកម្មរបស់ខ្លួនមិនបានគោរពតាមច្បាប់ ដែលរំលោភបំពានដល់សិទ្ធិមនុស្ស ហើយបញ្ហាទាំងអស់បង្កឲ្យមានការបាត់បង់ធនធានធម្មជាតិយ៉ាងសន្ធឹកសន្ធាប់ ដែលភាគច្រើននៃប្រជាពលរដ្ឋនៃប្រទេសកម្ពុជាគឺពឹងផ្អែកទៅលើការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ បញ្ហានេះរួមមាន ឧទាហរណ៍ ករណីឧស្សាហកម្មរ៉ែ និងកសិពាណិជកម្ម ដែលមិនគ្រាន់ទេបង្កឲ្យមានការរំលោទសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ការទន្ទ្រានយកដីជនជាតិដើមភាគតិត ដែលបង្កឲ្យមានវិវាទ ការផ្លាស់ទីលំនៅបុគ្គល ដោយមិនមានការផ្តល់នូវជីវភាពរស់នៅដោយជម្រើស និងនាំឲ្យមានការបំផ្លាញបរិស្ថាន។ យោងតាមស្ថានភាពទាំងនេះ យើងសូមជម្រុញយ៉ាងម៉ុតមាំ និងផ្តល់នូវអនុសាសន៍ ក្នុងការពង្រឹងក្របខណ្ឌច្បាប់ និងលើកកំពស់ការការពារសិទ្ធិមនុស្សក្នុងដំណើរការការលើកទឹកចិត្តក្នុងពាណិជ្ជកម្ម ការវិនិយោគ និងការអភិវឌ្ឍ ។

**អនុសាសន៍ដាក់ជូនរាជរដ្ឋាភិបាល៖**

- អនុវត្តឧបករណ៍វាយតម្លៃជាកាតព្វកិច្ចស្របច្បាប់ជាធរមាន ដូចជាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ដើម្បីជំរុញការទទួលខុសត្រូវរបស់សាជីវកម្មលើសង្គមនិងបរិស្ថាន។
- បន្ថយផលវិបាកនៃការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការបង្កើតច្បាប់ និង គោលនយោបាយនានាដែលផ្តល់អាទិភាពដល់ការប្រើប្រាស់ធនធានធម្មជាតិ តាមវិធីមួយដែលរក្សាសិទ្ធិរបស់សហគមន៍ក្នុងការប្រើប្រាស់ធនធានធម្មជាតិទាំងនេះ។ គោលនយោបាយទាំងនេះគប្បីមានឫសគល់ចេញពីអភិក្រមបែបចូលរួមនិងផ្អែកលើសិទ្ធិមនុស្ស។
- ការអនុវត្តនិងការប្រតិបត្តិច្បាប់និងគោលនយោបាយ គប្បីត្រូវបានពិនិត្យមើលឡើងវិញឲ្យបានទៀងទាត់ ដោយសហការជាមួយអង្គការសង្គមស៊ីវិល សហគមន៍និង ភាគីពាក់ព័ន្ធដទៃទៀត ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាព។

**អនុសាសន៍ចំពោះវិស័យឯកជន៖**

- អនុវត្តគណនេយ្យភាពសាជីវកម្ម តាមរយៈគោលនយោបាយដែលមានជាសាធារណៈ៖ រៀបចំគោលនយោបាយផ្ទាល់ខ្លួនដែលចែងលម្អិតអំពីការប្តេជ្ញារបស់ក្រុមហ៊ុនចំពោះការគោរពសិទ្ធិមនុស្ស និង អភិក្រមផ្អែកលើសិទ្ធិមនុស្សនៅក្នុងគម្រូធុរកិច្ចប្រតិបត្តិការវិស័យដោយឡែក។
- វិស័យឯកជនត្រូវតែពិគ្រោះយោបល់ជាមួយសហគមន៍និងភាគីពាក់ព័ន្ធ ដើម្បីកាត់បន្ថយវិវាទនិងផ្តល់អត្ថប្រយោជន៍សមស្របជូនដល់សហគមន៍ និង ទទួលស្គាល់ថាសមាជិកសហគមន៍ទាំងអស់គឺជាម្ចាស់សិទ្ធិ។
- កំណត់អាទិភាពនៃយុទ្ធសាស្ត្រនិងកិច្ចដំណើរការពាណិជកម្ម ដោយគិតគូរដល់ផលប៉ះពាល់នៃហានិភ័យសិទ្ធិមនុស្ស ពោលគឺមិនមែនការគិតគូរដល់សេដ្ឋកិច្ច ឬ ការគិតគូរផ្សេងៗទៀតឡើយ។
- ធានាឲ្យបាននូវការទទួលបានព័ត៌មានសម្រាប់ម្ចាស់សិទ្ធិទាំងអស់ និងថាភស្តុតាងនៃផលប៉ះពាល់ ទោះជារំពឹងទុកឬដែលអាចកើតមានក្តី ត្រូវបានផ្សព្វផ្សាយជូនដល់ជនរងផលប៉ះពាល់។
- ធានាឲ្យមានជំនាញឯកទេសនិងការយល់ដឹងគ្រប់គ្រាន់នៅក្នុងធុរកិច្ច ដើម្បីធានាឲ្យបាននូវការគោរពសិទ្ធិមនុស្ស និងអភិវឌ្ឍយន្តការនិងនីតិវិធីដោះស្រាយវិវាទ។ បើគ្មានការបណ្តុះបណ្តាល និងការកសាងចំណេះដឹងនៅក្នុងចំណោមនិយោជិត អំពីគោលយោបាយរបស់ក្រុមហ៊ុនស្តីពីគណនេយ្យភាពនិងសិទ្ធិមនុស្ស គោលនយោបាយនេះនឹងមានតែនៅលើក្រដាសប៉ុណ្ណោះ។
- វិភាជន៍ថវិកាផ្ទាល់ខ្លួនដើម្បីអនុវត្តយុទ្ធសាស្ត្រនានាសម្រាប់ការជំរុញយេនឌ័រជូនស្ត្រីនិងសហគមន៍។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**

**ក. ប្រជាសហគមន៍**

| | | | |
|---|---|---|---|
| ១.ក្រោស សុខ | ភេទប្រុស | ជនជាតិដើមភាគតិចព្នងខេត្តមណ្ឌលគិរី | ០៩៥ ៩៤៣ ៨១៧ |
| ២.ធីត ហូត | ភេទស្រី | ជនជាតិដើមភាគតិចព័រ ខេត្តបាត់ដំបង | ០៦១ ២៧៣៥ ៤៧ |
| ៣.ដៃ ជីម | ភេទប្រុស | ជនជាតិដើមភាគតិចជងខេត្តកោះកុង | ០៩៧ ៥៨៨៨ ៩៣៤ |
| ៤.ជុំ សុភឿត | ភេទប្រុស | ជនជាតិដើមភាគតិចកួយខេត្តព្រះវិហារ | ០១២ ៦២៩០៣៥ |
| ៥.តា វ៉ាងព្រៀវ | ភេទប្រុស | ជនជាតិដើមភាគតិចគ្រឹង ខេត្តរតនគិរី | ០១២ ៧១៣៦៦៩ |
| ៦.ទេព វន្នី | ភេទស្រី | សហគមន៍ដីធ្លីរាជធានីភ្នំពេញ | ០១២ ៦០៤៦៤៨ |
| ៧.ង៉ែត ឃុន | ភេទស្រី | សហគមន៍ដីធ្លីរាជធានីភ្នំពេញ | ០១៧ ៣៦០ ២៥១ |

**ខ. តំណាងអង្គការសង្គមស៊ីវិល**

| | |
|---|---|
| ១. លោក តឹក វណ្ណារ៉ា នាយកប្រតិបត្តិ NGOFORM | ០១២ ៧៩៣ ៤៨៩ |
| ២. លោក សួន ប៊ុនសក្តិ ប្រធានលេខាធិការដ្ឋាន CHRAC | ០៩២ ៣៤៤ ៣៥៧ |

**<u>បញ្ជីរាយនាម អង្គការសង្គមស៊ីវិល និងដៃគូរអភិវឌ្ឍន៍ គាំទ្រលើសេចក្តីថ្លែងការណ៍៖</u>**

១. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF)
២. គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា(CHRAC)
៣. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC)
៤. វិទ្យាស្ថានឥស្សរមតិនិងគោលនយោបាយ(API)
៥. សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូល ធនធាន(CRRT)
៦. ស្ម័គ្រចិត្តដើម្បីសង្គម(CVS)
៧. អង្គការអភិវឌ្ឍន៍និងភាពជាដៃគូរក្នុង សកម្មភាព (DPA)
៨. អង្គការយេនឌ័រនិងការអភិវឌ្ឍន៍ដើម្បីកម្ពុជា(GAD/C)
៩. ក្រុមការងារពិសេសសិទ្ធិ លំនៅឋាន (HRTF)
១០. អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច(ICSO)
១១. អង្គការយុវជនខ្មែរនិងការអភិវឌ្ឍន៍ សង្គម(KYSD)
១២. អង្គការជីវិតថ្លៃថ្នូរ(LWD)
១៣. អង្គការស្តារកម្ពុជា(Star Kampuchea)
១៤. អង្គការវីជីឡែន (Vigilance)
១៥. អង្គការទស្សនៈពិភពលោក (WVC)
១៦. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន(YRDP)
១៧. អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង(UPWD)
១៨. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍(CLEC)
១៩. អង្គការភូមិខ្ញុំ (MVi)

២០. អង្គការផ្លាស់ប្តូរបទពិសោធន៍ អនុផលព្រៃឈើ (NTFP-EP)
២១. អង្គការពន្លកខ្មែរ (PKH)
២២. អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា (SVC)
២៣. អង្គការសមាគមន៍ខ្មែរលើ- រតនគិរី (HA)
២៤. អង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO)
២៥. សមាគមន៍យុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA)
២៦. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
២៧. អង្គការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ (CED)
២៨. អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ (AFD)
២៩. ក្រុមទ្រទ្រង់ភូមិ (VSG)
៣០. សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)
៣១. អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (BCV)
៣២. អង្គការអភិវឌ្ឍន៍សហគមន៍ដើម្បីសន្តិភាព និងនិរន្តរភាព (CDPS-CPN)
៣៣. អង្គការអនុផលព្រៃឈើ (NTFP)
៣៤ អង្គការអប់រំបរិស្ថាន (Live and Learn)
៣៥. វីនរ៉ក់ (Winrock)
៣៦. ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រជាជនសហរដ្ឋអាមេរិក ( USAID)
៣៧. អង្គការ (PACT)
៣៨ អង្គការអុកស្វាម (OXFAM in Cambodia)
៣៩. អង្គការជំនួយវិហារដាណឺម៉ាក/ជំនួយគ្រីស្ទាន (DCA)
៤០. អង្គការអភិវឌ្ឍន៍ជនបទ ភូមិភាគឦសាន(NRD)
៤១. អង្គការដាយកូនៀ (Diakonia)
៤២. អង្គការ(DANMISSION)
៤៣. សមាគមថែរក្សាបរិស្ថាន និងវប្បធម៌(CEPA)
៤៤. អង្គការនាគព័ន្ធដើម្បីអភិវឌ្ឍ
៤៥. អង្គការទឹកដីសុវណ្ណភូមិ (TDSP)
៤៦. អង្គការសមធម៌កម្ពុជា (EC)
៤៧. សមាគមយុវជនខ្មែរ (KYA)